**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**
សំណុំរឿងរដ្ឋប្បវេណីលេខ ៥១
ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១
**សាលក្រមរដ្ឋប្បវេណី**
**លេខ: ១៨ (ថ)/១២៦**
ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តសៀមរាប**

បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់ម៉ាត់ជាសាធារណៈ នៅសាលសវនាការ
លេខ ខ (២) នៃសាលាដំបូងខេត្តសៀមរាប
បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១
កាលបរិច្ឆេតប្រកាសសាលក្រមថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូង

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជី

**ដើមចោទ**

-ឈ្មោះ [redacted] រីតា ភេទស្រី អាយុ ៣២ឆ្នាំ ជនជាតិខ្មែរ ។
អាសយដ្ឋានបច្ចុប្បន្នស្ថិតនៅ[redacted] ។
-មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] អត្តលេខ: ៧៣៩ ទីលំនៅបច្ចុប្បន្ន [redacted] ។

**ចុងចម្លើយ**

-ឈ្មោះ [redacted] សុវត្ថិ ភេទប្រុស អាយុ ៤៧ឆ្នាំ ជនជាតិខ្មែរ ។
អាសយដ្ឋានបច្ចុប្បន្នស្ថិតនៅ[redacted]។
-មេធាវីតំណាងដោយអាណត្តិឲ្យសហចុងចម្លើយឈ្មោះ [redacted] អត្តលេខ[redacted]អាសយដ្ឋានបច្ចុប្បន្ន[redacted] ។

**អំពីអង្គហេតុ និងចំណុចវិវាទ**

**I-សាលក្រមដែលទាមទារដោយដើមចោទ:**

ដើមចោទសុំប្តឹងឱ្យសាលាដំបូងខេត្តសៀមរាបចេញសាលក្រមសម្រេចដូចតទៅ:

**ក**-ឲ្យដើមចោទឈ្មោះ [redacted] រីតា មានសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិលើដីមួយ កន្លែងដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២២០៤០៣១៦-០៥៣៧ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ ស្ថិតនៅភូមិដងទង់ សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តមានជ័យ ។

**ខ**-ឲ្យដើមចោទទទួលបន្ទុកបង់ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តី ។

**គ**-បង្គាប់ឲ្យប្រកាសជាបណ្តោះអាសន្ននូវចំណុចទី ១ នៃកម្មវត្ថុខាងលើ ។



Scanned with CamScanner

II-ការពន្យល់ត្រួសៗអំពីដំណើររឿងក្តី

កាលពីថ្ងៃទីអំឡុងឆ្នាំ២០០៥ ឈ្មោះ [redacted] វីតា និងឈ្មោះ [redacted] សុវត្ថិ បានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមប្រពៃណី និងបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ០១ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥ និងមានកូនចំនួន ០៣ នាក់ ប្រុស ០១នាក់ និងស្រី ០២នាក់ រួមមានដីពីរកន្លែងជាទ្រព្យសម្បត្តិរួមគឺ ដីដែលមានវិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុលេខ ២២០៤០៣១៦-០៥៣៧ ស្ថិតនៅភូមិដងទង់ សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ និងដីដែលមានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ ២២០៤៣១៦-០៥៨១ ស្ថិតនៅភូមិដងទង់ សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ ។

នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ភាគីបានដាក់ពាក្យបណ្តឹងលែងលះនៅសាលាដំបូងខេត្តសៀមរាប ហើយនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ សាលាដំបូងខេត្តសៀមរាប បានសម្រេចចេញសាលាក្រមរដ្ឋប្បវេណី លេខ ០៦ (គ) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ ដោយសម្រេចឲ្យលែងលះហើយប្រគល់ដីក្បាលលេខ ០៥៨១ ឲ្យទៅឈ្មោះ [redacted] វីតា ជាអ្នកគ្រប់គ្រង តែជាក់ស្តែងក្បាលដីលេខ ០៥៨១ បានលក់បាត់ហើយ នៅឡើយតែក្បាលដីលេខ ០៥៣៧ ដែលមិនទាន់បានលក់ និងជាទ្រព្យសម្បត្តិរួម ដែលត្រូវប្រគល់មកឲ្យឈ្មោះ [redacted] វីតា ជាអ្នកគ្រប់គ្រង ។

III-ការអះអាងរបស់ដើមចោទ

-ដើមចោទឈ្មោះ [redacted] វីតា បានធ្វើការអះអាងថា៖ ដីដែលមានក្បាលដីលេខ ០៥៨១ បានលក់បាត់ហើយក្នុងតម្លៃជាង ១០,០០០ ដុល្លារអាមេរិក ដោយលុយឈ្មោះ [redacted] សុវត្ថិ បានអោយខ្លួនតែ ៣,០០០ ដុល្លារអាមេរិក ហើយឈ្មោះ [redacted] សុវត្ថិ ថាអោយជាដំណាក់កាលតែពេលនេះគឺបាត់រហូត ហើយមិនដឹងថាលុយបន្តបន្ទាប់គាត់យកទៅណាទេ ។ ដីនោះលក់ពេលមុនលែងលះនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ ។ ចំពោះដីដែលមានក្បាលដីលេខ ០៥៣៦ ជាឈ្មោះ [redacted] ជីវ័ន្ត ប៉ុន្តែដីនោះជារបស់អ៊ីខ្លួនទេ ពេលចេញជាប្លង់រឹងគាត់ដាក់ឈ្មោះ [redacted] ជីវន្ត ដោយសារជាបងប្អូនជីដូនមួយរបស់គាត់ ហើយបច្ចុប្បន្នឈ្មោះ [redacted] សុវត្ថិ ជាអ្នកកាន់កាប់ តែឈ្មោះ [redacted] ជីវន្ត មិនមែនជាម្ចាស់ទេ ។ ក្បាលដីលេខ ០៥៣៦ ដែលកាន់អោយឈ្មោះ [redacted] សុវត្ថិ ខ្លួនពុំមានឯកសារបញ្ជាក់ទេ តែខ្លួនបានអោយប្លង់ទៅឈ្មោះ [redacted]ុវត្ថិ ហើយ ។ ក្បាលដីលេខ ០៥៣៧ ឈ្មោះ [redacted] សុវត្ថិ កាន់កាប់ ។ ពេលលែងលះគឺចែកគ្នាម្នាក់មួយប្លង់ ដោយក្បាលដីលេខ ០៥៣៦ អោយទៅឈ្មោះ [redacted] សុវត្ថិ ចំណែកក្បាលដីលេខ ០៥៣៧ អោយមកខ្លួន ។ ទាក់ទង់ដីក្បាលដីលេខ ០៥៣៧ ដែលថាតុលាការសម្រេចអោយខ្លួន និងក្បាលដីលេខ ០៥៣៦ សម្រេចឲ្យឈ្មោះ [redacted] សុវត្ថិ ខ្លួនមិនដឹងថាហេតុអ្វីមិនមាននៅក្នុងសាលក្រមទេ ខ្លួនមានតែសាក្សីមកអះអាង ។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិរបស់ដើមចោទឈ្មោះ [redacted] វីតា បានធ្វើសេចក្តីថ្លែងកាណ៍ថា៖ ខ្លួនសុំធ្វើការថ្លែងការណ៍ដូចអ្វីដែលមាននៅក្នុងពាក្យបណ្តឹងរបស់ខ្លួនដែលបានដាក់ចូលមកតុលាការ និងសុំបន្ថែមនូវកម្មវត្ថុនៃការទាមទារគឺឲ្យចុងចម្លើយរុះរើអីវ៉ាន់ និងសម្ភារៈផ្សេងៗដែលមាននៅលើដីនោះ សុំបញ្ជាក់ថាអង្គហេតុដែលមាននៅក្នុងពាក្យបណ្តឹង គឺពាក់ព័ន្ធនិងអង្គហេតុនៅក្នុងសាលក្រមលេខ ៦ (គ) ចុះថ្ងៃទី ០៥ ខែមីនា ឆ្នាំ ២០២០ ដីដែលមានក្បាលលេខ ០៥៨១ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២២០៤០៣១៦-០៥៨១ ស្ថិតនៅភូមិដងទង់ សង្កាត់



Scanned with CamScanner

កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ ដែលសម្រេចអោយកូនក្តីខ្លួនមានសិទ្ធិគ្រប់គ្រង ចាត់ចែងជាកម្មសិទ្ធិ ត្រូវបានចុងចម្លើយលក់បាត់អស់ហើយ ដូច្នេះកូនក្តីខ្លួនមានតែទ្រព្យមួយដែលជាកម្មវត្ថុនៃការទាមទារនេះទេ ដែលត្រូវផ្គត់ផ្គង់គ្រួសារ ចិញ្ចឹមកូន ហើយជាក់ស្តែងពេលបច្ចុប្បន្នប្លង់ដីខាងលើគឺនៅលើកូនក្តីខ្លួនគ្រប់គ្រង ។ លើសពីនេះនៅក្នុងសាលក្រមលេខ ៦ (គ) ចុះថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០២០ ពុំបានសម្រេច និងប្រគល់អោយកូនក្តីខ្លួនទេ ។

ក្នុងនីតិវិធីត្រៀមឃើញថាតុលាការបានកំណត់ចំណុចវិវាទថា តើដើមចោទអាចធ្វើលទ្ធកម្មកម្មសិទ្ធិតែម្នាក់ឯងបានដែរឬទេ ? ពាក់ព័ន្ធនឹងកម្មវត្ថុនៃការទាមទារគឺទី១ អោយដើមចោទឈ្មោះ [redacted] វីតា មានសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិលើដីមួយ កន្លែងដែលមាន វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២២០-៤០៣១៦-០៥៣៧ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ ស្ថិតនៅភូមិដងទង់ សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តមានជ័យ ទី២ ឲ្យដើមចោទទទួលបន្ទុកបង់ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តី និងទី៣ បង្គាប់ឲ្យប្រកាសជាបណ្តោះអាសន្ននូវចំណុចទី១ នៃកម្មវត្ថុខាងលើអញ្ចឹងកម្មវត្ថុនៃការទាមទារគឺពុំមានការផ្លាស់ប្តូរទេហើយចំពោះសេចក្តីថ្លែងការណ៍ គឺសុំរក្សាដូចអ្វីដែលបានថ្លែងការណ៍ក្នុងនីតិវិធីត្រៀមដដែល តែអ្វីដែលខ្លួនស្នើសុំគឺពិនិត្យភស្តុតាងជាសាក្សីដែលបានអញ្ជើញមក ។

ខ្លួនសុំប្រានចោលសេចក្តីថ្លែងការណ៍របស់មេធាវីចុងចម្លើយ ដោយហេតុថានៅក្នុងសាលក្រមពាក់ព័ន្ធការលែងលះដែលមានដីមួយកន្លែង ដែលប្រគល់មកអោយដើមចោទនេះ ជាការភ័ណ្ឌច្រឡំទេក្បាលដីដែលមានលេខ ០៥៨១ នេះគឺត្រូវបានលក់រួចទៅហើយ លក់មុនសេចក្តីសម្រេចលែងលះទៀតហេតុអ្វីសម្រេចឲ្យកូនក្តីខ្លួនទៀត ។ លក់ដីនោះដោយសារភាគីប្តីប្រពន្ធបានឯកភាពគ្នាថាយកដីមួយនោះទៅលក់យកលុយមកប្រើប្រាស់ រួចហើយក្បាលដីដែលមានលេខ ០៥៣៦ គឺប្រគល់អោយឈ្មោះ [redacted] សុវត្ថិ ចំណែកក្បាលដីដែលមានលេខ ០៥៣៧ គឺប្រគល់អោយកូនក្តីខ្លួន ។ ការចែកគ្នាតាមការព្រមព្រៀងដែលមានសាក្សីដែលអាចបំភ្លឺបាន ។ នៅក្នុងសាលក្រមពុំបានសសេរ ហើយក្រោយពេលដាច់ស្រាប់ចុងចម្លើយបានបោះពាក្យថាយកប្លង់យកចុះគាត់យកដី ។ អញ្ចឹងខ្លួនសុំលោកចៅក្រមពិនិត្យភស្តុតាងនៅក្នុងសាលក្រមគឺដីដែលមានក្បាលដីលេខ ០៥៨១ អញ្ចឹងគឺមិនអាចយកមកបែងចែកអោយកូនក្តីខ្លួនបានទៀតទេ ។ ចំណែកដីដែលមានក្បាលដីលេខ ០៥៣៧ គឺប្លង់នៅលើកូនក្តីខ្លួននៅឡើយ ដោយសារព្រមព្រៀងចែកគ្នាទើបប្រគល់ប្លង់អោយគ្នា ។

ខ្លួនសុំប្រានចោលពាក្យបណ្តឹងតប ដោយសារពាក្យបណ្តឹងមិនត្រឹមត្រូវ និងមិនស្របច្បាប់ ។

IV-**ការអះអាងរបស់ចុងចម្លើយ**

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយឈ្មោះ [redacted] សុវត្ថិ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនសុំឆ្លើយដូចអ្វីដែលមាននៅក្នុងសេចក្តីថ្លែងការណ៍ដែលបានដាក់ចូលតុលាការនៅនីតិវិធីត្រៀមក្នុងពាក្យបណ្តឹងដើមទាំងស្រុង និងសុំបន្ថែមដូចតទៅ:

ចំណុច ក សាលក្រមរដ្ឋប្បវេណីលេខ ៦ (គ) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ សម្រេចប្រគល់ដីដែលមានក្បាលដីលេខ ០៥៨១ ទៅឲ្យដើមចោទគឺពុំមានចំណុចណាមួយដែលមានការភ័ណ្ឌច្រឡំឡើយ ដោយហេតុថាទាំងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ដើមចោទឈ្មោះ [redacted] វីតា បានធ្វើការទាមទារលើក្បាលដីលេខ ០៥៨១ តែមួយប៉ុណ្ណោះ មិនមានពាក់ព័ន្ធ



Scanned with CamScanner

ជាមួយក្បាលដីលេខ ០៥៣៧ នោះឡើយ ម្យ៉ាងទៀត សាលក្រមរដ្ឋប្បវេណីលេខ ៦ (គ) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ សម្រេចប្រគល់ដីដែលមានក្បាលដីលេខ ០៥៨១ ទៅឲ្យដើមចោទរួចហើយ បើទោះបីបានលក់មុន សាលក្រមលែងលះក៏ដោយតែដើមចោទជាអ្នកគ្រប់គ្រងសាច់ប្រាក់ដែលបានលក់នោះ រីឯចុងចម្លើយពុំបានគ្រប់គ្រងសាច់ប្រាក់នោះទេ ។

ចំណុច ខ ដីដែលមានក្បាលដីលេខ ០៥៣៧ ជាទ្រព្យរួមដែលកើតមានក្នុងអំឡុងពេលអាពាហ៍-ពិពាហ៍ដែលច្បាប់បានកំណត់ថាក្រោយពេលលែងលះទ្រព្យរួមត្រូវបែងចែកជាពីរចំណែកស្មើគ្នាតាមមាត្រា ៩៨០ កថាខណ្ឌ ២ នៃក្រមរដ្ឋប្បវេណី ។

ចំណុច គ ចុងចម្លើយបានបង់អាហារកិច្ចចិញ្ចឹមកូនរហូតមក ជាពិសេសចុងចម្លើយបានរៀបចំដីដែលមានក្បាលដីលេខ ០៥៣៧ ជាដីចំការ ដែលមានបំណងបង្កើតជាផលរបរមួយដែលអាចផ្គត់ផ្គង់ខ្លួនបាន និងដល់កូនៗ នៅពេលអនាគត់ ។

ចំណុច ឃ ចុងចម្លើយមានជីវភាពក្រីក្រដោយពឹងទៅលើការធ្វើដំណាំលើក្បាលដីលេខ ០៥៣៧ នេះ ដើម្បីដោះស្រាយបញ្ហាជីវភាពប្រចាំថ្ងៃ បើប្រគល់ដីនោះទៅឲ្យដើមចោទទាំងអស់ធ្វើអោយចុងចម្លើយក្លាយទៅជាជនក្រីក្រពុំមានទីសំណាក់ស្នាក់អាស្រ័យ ហើយវាជាការបំពានលើបញ្ញត្តិមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី ព្រោះចុងចម្លើយទាមទារអោយមានការចែងចែកទ្រព្យជាពីរចំណែកស្មើរគ្នា ។

ខ្លួនសុំច្រានចោលសេចក្តីថ្លែងការណ៍របស់លោកមេធាវីតំណាងឲ្យដើមចោទ ទាក់ទងក្បាលដីដែលមានលេខ ០៥៣៧ នេះ ទី១ ពុំមានការសម្រេចសេចក្តីក្នុងសាលក្រមលែងលះទេ ទី២ ភាគីបានលក់ដីដែលក្នុងសាលក្រមលែងលះបានប្រគល់អោយតែក្នុងការលក់នេះគឺដើមចោទ ទាំងចុងចម្លើយលក់ជាមួយគ្នាហើយសាច់ប្រាក់គាត់ជាអ្នកគ្រប់គ្រងនិងចាត់ចែងចំណែកកូនក្តីខ្លួនពុំបានគ្រប់គ្រងទេ ចំណែកដីដែលមានក្បាលដីលេខ ០៥៣៦ ដែលគាត់បានលើកឡើងថាបានព្រមព្រៀងប្រគល់មកអោយកូនក្តីខ្លួន ចំណុចនេះប្រគល់របៀបណាបើដីនោះជាកម្មសិទ្ធិរបស់អ្នកដទៃ អញ្ចឹងកូនក្តីខ្លួនមានសិទ្ធិអ្វីទៅយកដីរបស់អ្នកដទៃ ។

ខ្លួនសុំរក្សាការទាមទារនៅក្នុងពាក្យបណ្តឹងតបទាំងស្រុង និងសុំបន្ថែមខ្លឹមសារដូចតទៅៈ ក្រោយពីដើមបណ្តឹងតប និងចុងបណ្តឹងតប បានលែងលះគ្នារួចហើយកូនក្តីខ្លួនឈ្មោះ [redacted] សុវត្ថិ បានចូលទៅកាន់កាប់និងអាស្រ័យផលលើដីដែលមានក្បាលដីលេខ ០៥៣៧ ដែលជាក់ស្តែងដីនោះពីដំបូងឡើយមានព្រៃច្រើនក្នុងនោះកូនក្តីខ្លួនបានឈូសឆាយសំអាតព្រៃ និងធ្វើផ្លូវ រៀបចំដីក្លាយជាដីចំការមានដំណាំដោយបានជីស្រះ ហើយការចំណាយទាំងអស់មានចំនួន ១២៨២៥ ដុល្លារអាមេរិក ដែលបានកែប្រែដីព្រៃទៅជាដីកសិកម្ម ដូច្នេះចុងបណ្តឹងតប ត្រូវសងប្រាក់ចំនួនពាក់កណ្តាលនៃសោហ៊ុយ ដែលកូនក្តីខ្លួនបានចំណាយ ដើម្បីគ្រប់គ្រងលើដីនោះនូវទឹកប្រាក់ចំនួន ៦៤២០ ដុល្លារអាមេរិក ទៅឲ្យកូនក្តីខ្លួនវិញតាមបញ្ញត្តិមាត្រា ២០៩ កថាខណ្ឌ ២ នៃក្រមរដ្ឋប្បវេណី ដែលការទាមទារនេះមានការភ្ជាប់មកជាមួយភស្តុតាងដែលបានដាក់ចូលមកនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ ហើយវិក្កយប័ត្រទាក់ទងការចំណាយលើការសម្អាតដី ។

V-**ការអះអាងរបស់សាក្សី**

-សាក្សីឈ្មោះ [redacted] ជី បានធ្វើសេចក្តីអះអាងថា៖ ខ្លួនត្រូវជាអ៊ីបង្កើតរបស់ឈ្មោះ [redacted] វីតា ខ្លួន



Scanned with CamScanner

បានស្សថ្យចរាល់ហើយ ។ ខ្លួនដឹងថាដីមានមួយកន្លែងពុំមានដីផ្សេងទៀតទេ នៅខេត្តឧត្តរមានជ័យ ដោយមានក្បាលដីលេខ ០៥៨១ បានលក់បាត់ហើយ ចំណែកដីមិនទាន់លក់មានក្បាលដីលេខ ០៥៣៦ និងលេខ ០៥៣៧ ។ ក្បាលដីលេខ ០៥៣៦ ឈ្មោះ [redacted] ជីវ័ន្ត បងប្អូនខាងឈ្មោះ [redacted] សុវត្ថិ តែជាក់ស្តែងដីនោះទិញរួមបងប្អូនខ្លួនទេ ដោយគិតថាបើលក់បានចែកភាគរយគ្នា ។ ពេលលែងលះដោយគិតថាដីនោះមានឈ្មោះ [redacted] ជីវ័ន្ត ជាបងប្អូនឈ្មោះ [redacted] សុវត្ថិ ទើបប្រគល់អោយឈ្មោះ [redacted] សុវត្ថិ ។ ដីក្បាលលេខ ០៥៣៧ ប្លង់នៅលើខ្លួន តែដីជាក់ស្តែងឈ្មោះ [redacted] សុវត្ថិ កាន់កាប់ ដែលមានទំហំ ៩ ហិចតាជាង និងក្បាលដីលេខ ០៥៣៦ មានទំហំ ៨ ហិចតាជាង ។ ពេលលែងលះដឹងថាចែកគ្នាដោយក្បាលដីលេខ ០៥៣៦ អោយឈ្មោះ [redacted] សុវត្ថិ និងក្បាលដីលេខ ០៥៣៧ អោយឈ្មោះ [redacted] វីតា ទុកចិញ្ចឹមកូន ពេលចប់សព្វគ្រប់អស់ហើយប្ដីនោះជិះមកយកប្លង់ពីខ្លួន ។ ការបែងចែកដីគឺមានការឯកភាពគ្នាអស់ហើយតែខ្លួនពុំមានឯកសារបញ្ជាក់ទេគឺក្មួយខ្លួននិយាយប្រាប់ ។

-សាក្សីឈ្មោះ [redacted] នួន បានធ្វើសេចក្តីអះអាងថា៖ ខ្លួនជាអ៊ីបង្កើតរបស់ដើមចោទ ។ ក្នុងរឿងនេះឈ្មោះ [redacted] វីតា និងឈ្មោះ [redacted] សុវត្ថិ មានក្បាលដីពីរប្លង់ និងឈ្មោះ [redacted] ជីវ័ន្ត មួយទៀត ទាំងអស់បីប្លង់ ប៉ុន្តែលក់អស់មួយហើយនៅសល់ពីរប្លង់ទៀត ។ ខ្លួនដឹងរឿងថាដីឈ្មោះ [redacted] ជីវ័ន្ត នោះទុកអោយឈ្មោះ [redacted] សុវត្ថិ ហើយដីដែលមានឈ្មោះ [redacted] វីតា និងឈ្មោះ [redacted] សុវត្ថិ គឺទុកអោយឈ្មោះ [redacted] វីតា ទុកចិញ្ចឹមកូន ខ្លួនដឹងរឿងដោយសារក្រឡាបញ្ជីប្រាប់ ។ ដំបូងក្បាលដីមានតែពីរទេតែក្រោយពីខ្លួនឡើងទៅវាស់ឃើញខុសក្បាលដី ពេលត្រឡប់មកវិញឃើញក្បាលដីមានបី ។ ក្បាលដីលេខ ០៥៣៧ ទុកអោយកូនដោយក្មួយជាអ្នកទូរស័ព្ទប្រាប់។ ការបែងចែកដោយការព្រមព្រៀងនោះខ្លួនពុំមានឯកសារបញ្ជាក់ទេ ។

-សាក្សីឈ្មោះ [redacted] សុខផល្លា បានធ្វើសេចក្តីអះអាងថា៖ ខ្លួនជាអ្នករស់នៅជិតខាងគ្នាជាសាច់ញាតិរបស់ឈ្មោះ [redacted] វីតា ហើយវាពាក់ព័ន្ធជាមួយដីខ្លួនដែរ ។ ក្នុងរឿងទាមទារដី ខ្លួនធ្លាប់ទិញដីជាមួយឈ្មោះ [redacted] សុវត្ថិ ដែរតែក្រោយមកដោយសារដីមិនគ្រប់ ក៏នាំគ្នាប្រមូលដីនោះមកទុកជុំគ្នាបើលក់បានចែកគ្នាតាមចំណែករៀងខ្លួន តែដល់ពេលពួកគាត់មានរឿងដោយសារដីនោះក៏លែងលះគ្នា ហើយពេលលែងលះគ្នាប្រាប់ថាដីនោះចែកគ្នាអស់ហើយ តែពេលទៅវាស់ជើងម៉ែត្រចែកគ្នានៅសុរិយោដី ឃើញថាដីក្បាលលេខ ០៥៨១ បានលក់បាត់ហើយ អញ្ចឹងខាងសុរិយោដីវាស់វែងទៅឈ្មោះ [redacted] សុវត្ថិ ក៏ទៅរស់នៅលើដីដែលមានក្បាលដីលេខ ០៥៣៧ ប៉ុន្តែពេលដែលគាត់ថាបែងចែកគ្នានោះគឺឈ្មោះ [redacted] ជីវ័ន្ត ក្បាលដីលេខ ០៥៣៦ គឺទុកសម្រាប់ឈ្មោះ [redacted] សុវត្ថិ ចំណែកដីដែលមានក្បាលដីលេខ ០៥៣៧ គឺទុកសម្រាប់ឈ្មោះ [redacted] វីតា ចិញ្ចឹមកូន ។ ក្បាលដីដែលមានលេខ ០៥៣៧ ឈ្មោះ [redacted] វីតា មិនបានចាំក្បាលដីទេ គឺគាត់គ្រាន់តែដឹងថាដីដែលមានឈ្មោះ [redacted] ជីវន្ត គឺទុកសម្រាប់ឈ្មោះ [redacted] សុវត្ថិ ចំណែកដីដែលមានឈ្មោះ [redacted] វីតា និងឈ្មោះ [redacted] សុវត្ថិ គឺទុកអោយឈ្មោះ [redacted] វីតា សម្រាប់ចិញ្ចឹមកូន ។ បច្ចុប្បន្នប្លង់ដីទាំងអស់គឺអ៊ីៗអ្នករក្សាទុក ចំណែកដីជាក់ស្តែងឈ្មោះ [redacted] សុវត្ថិ ទៅកាន់កាប់ និងដាំដុះ ។ ការបែងចែកក្បាលដីទៅឈ្មោះ [redacted] វីតា និងឈ្មោះ [redacted] សុវត្ថិ តាមរយៈក្រឡាបញ្ជី ។ ពេលដែលពួកខ្លួនទៅវាស់វែងដីដែលមានក្បាលដីលេខ ០៥៣៧ នោះឈ្មោះ [redacted] សុវត្ថិ បាននិយាយថាដីនោះជាដីរបស់គាត់ ហើយគាត់នាំប្រពន្ធក្រោយទៅរស់នៅដាំដុះលើដីនោះទៀត ។ ពេលដែលខ្លួនមកជួបក្រឡាបញ្ជីគាត់បានប្រាប់ថាគាត់គ្មានសិទ្ធិបែងចែកដីដែលមានក្បាលដីលេខ ០៥៣៦ ទេព្រោះជាដីរបស់គេ តែជាក់ស្តែងដីនោះគឺ

យកឈ្មោះគេដាក់ទេ ការពិតដីនោះជាដីរបស់គាត់ ។ ដីដែលមានក្បាលដីលេខ ០៥៣៦ បច្ចុប្បន្នឈ្មោះ [redacted] សុវត្ថិ ជាអ្នកគ្រប់គ្រង ហើយដីដែលមានក្បាលដីលេខ ០៥៣៧ ក៏ឈ្មោះ [redacted] សុវត្ថិ ជាអ្នកគ្រប់គ្រង ហើយរស់នៅលើនោះទៀត ចំណែកប្លង់ដីដែលមានក្បាលដីលេខ ០៥៣៧ គឺខាងខ្លួនជាអ្នកគ្រប់គ្រង ។ ចំពោះដីដែលមានក្បាលដីលេខ ០៥៣៧ ដែលខ្លួនដឹងថាឈ្មោះ [redacted] សុវត្ថិ ជាអ្នកគ្រប់គ្រងដោយសារពួកខ្លួនចុះទៅដល់កន្លែងដី ។ ចំពោះដីដែលមានក្បាលដីលេខ ០៥៣៦ មានឈ្មោះអ្នកដទៃតែការពិតជាដីរបស់ខ្លួនទាំងអស់គ្នាហើយឈ្មោះ [redacted] ជីវ័ន្ត ពុំបានមកទាមទារនោះទេ ។

**VI-សេចក្តីថ្លែងការណ៍ចុងក្រោយរបស់មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទ**

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍ចុងក្រោយទាំងបណ្តឹងដើម និងបណ្តឹងតបថា: ពាក់ព័ន្ធក្នុងរឿងនេះឃើញថាមានភាពស៊ីសង្វាក់គ្នាថាដីដែលមានក្បាលដីលេខ ០៥៣៧ គឺភាគីពិតជាបានប្រគល់មកអោយឈ្មោះ [redacted] វីតា ជាអតីតប្រពន្ធពិតប្រាកដមែន ព្រោះពេលភាគីបានព្រមព្រៀងគ្នាគឺបានបែងចែកប្លង់ដីរួចរាល់ហើយព្រោះមានការលែងលះចប់សព្វគ្រប់ហើយ បើគ្មានការបែងចែកទេប្លង់ដីក៏មិនទាន់មានការបែងចែកដែរ អញ្ចឹងដោយសារភាគីបានព្រមព្រៀងគ្នារួចទៅហើយ បានមានឈានដល់ការប្រមូលប្លង់ដីដើម្បីគ្រប់គ្រងដីរៀងខ្លួនៗ ។ ជាក់ស្តែងដីដែលមានក្បាលដីលេខ ០៥៣៦ បានប្រគល់ទៅអោយឈ្មោះ [redacted] សុវត្ថិ ដោយសារតែក្នុងប្លង់ដីនោះមានឈ្មោះ [redacted] ជីវ័ន្ត ជាបងប្អូនខាងឈ្មោះ [redacted] សុវត្ថិ តែម្តង អញ្ចឹងវាងាយស្រួល ចំណែកទំហំដីប្រហាក់ប្រហែលគ្នា ខុសគ្នាជាង ១ ហិចតា ហើយភាគីឈ្មោះ [redacted] វីតា បានដីលើសជាង ១ ហិចតា តែទុកសម្រាប់ផ្គត់ផ្គង់ចិញ្ចឹមកូនព្រោះគាត់ទទួលបន្ទុកកូន ហើយជាក់ស្តែងក្បាលដីលេខ ០៥៨១ គឺភាគីបានលក់បាត់ហើយដោយមានលិខិតយថាភូតបញ្ជាក់ស្រាប់ អញ្ចឹងសាលក្រមលែងលះហេតុអ្វីបានសម្រេចប្រគល់ដីដែលលក់បាត់ហើយមកអោយកូនក្តីខ្លួនអញ្ចឹងវាខុស ហើយនៅទីនេះមានសាក្សីបីនាក់ ដែលពីរនាក់ជាសាច់ញាតិនិងម្នាក់ជាអ្នកជិតខាង និយាយរួមទ្រព្យសម្បត្តិទាំងអស់នេះគឺជាទ្រព្យរបស់ពួកគាត់ទាំងអស់គ្នាដែលបានយកលុយទៅទិញដីនោះមក អញ្ចឹងគាត់ឆ្លើយស៊ីសង្វាក់គ្នាថាពិតជាមានការបែងចែកដីមែនហើយប្រគល់ដីលេខ ០៥៣៧ មកអោយឈ្មោះ [redacted] វីតា មែននេះជាភស្តុតាងនិងសាក្សីក្នុងការទាមទារ ។

ចំពោះពាក្យបណ្តឹងតប ខ្លួនសុំច្រានចោលការទាមទារ ដោយសារពាក្យបណ្តឹងតបផ្ទុយច្បាប់ ដោយសារក្នុងកំណត់ហេតុត្រៀមបានកំណត់រយៈពេលដាក់ភស្តុតាងរួចហើយ ។

**VII-សេចក្តីថ្លែងការណ៍ចុងក្រោយរបស់មេធាវីតំណាងដោយអាណត្តិចុងចម្លើយ**

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ចុងក្រោយទាំងបណ្តឹងដើម និងបណ្តឹងតបថា: ខ្លួននៅតែរក្សាទុកការទាមទារ ទៅតាមខ្លឹមសារនៃសេចក្តីថ្លែងការណ៍ក្នុងនីតិវិធីត្រៀម នៅក្នុងបណ្តឹងដើម ហើយនិងរក្សាការទាមទារចំពោះខ្លឹមសារនៅក្នុងបណ្តឹងតប នៅដដែល បន្ថែមពីនេះទាក់ទងទៅនឹងសាក្សីទាំងបីនាក់ដែលគាត់បានឆ្លើយបំភ្លឺនៅក្នុងរឿងក្តីនេះឃើញថាចម្លើយរបស់គាត់មិនមានចំណុចណាមួយដែលបញ្ជាក់ច្បាស់អំពីការព្រមព្រៀងគ្នាក្នុងការបែងចែកដី នៃក្បាលដីលេខ ០៥៣៦ និងក្បាលដីលេខ ០៥៣៧ នោះឡើយដូច្នេះខ្លួនសុំច្រានចោលភស្តុតាងជាសាក្សីរបស់ដើមចោទទាំងបីរូបដោយសុំអោយចៅក្រមមិនយកភស្តុតាងនេះមកធ្វើការពិចារណាក្នុងការសម្រេចសេចក្តីក្នុងសាលក្រម ដោយសាក្សីទាំងនេះជាសាច់ញាតិរបស់ដើមចោទហើយពុំមានលិខិតយថាភូត ឬ



Scanned with CamScanner

លិខិតឯកជនណាមួយដែលបញ្ជាក់អំពីការបែងចែកទ្រព្យរួមនេះឡើយ ។ ជាចុងបញ្ចប់ខ្លួនសុំសំណូមពរលោកចៅក្រម ឲ្យសម្រេចសេចក្ដីឲ្យកូនក្ដីខ្លួនដូចការទាមទារនៅក្នុងសេចក្ដីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមនៅក្នុងបណ្ដឹងដើមក៏ដូចជាសម្រេចការទាមទារនៅក្នុងបណ្ដឹងតបដោយក្ដីអនុគ្រោះ ។

**ចំណុចវិវាទ**

១-តើដើមចោទអាចធ្វើលទ្ធកម្មកម្មសិទ្ធិតែម្នាក់ឯងបានដែរឬទេ ?

VII-**ការពិនិត្យភស្តុតាង**

១-សាលក្រមលេខ ០៦ (គ) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តសៀមរាប ។

២-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២២០៤០៣១៦-០៥៣៧ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តឧត្តរមានជ័យ ។

៣-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២២០៤០៣១៦-០៥៣៦ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ របស់ប្រធានមន្ទីររៀបចំដែនដីនគររូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តឧត្តរមានជ័យ ។

៤-លិខិតបញ្ជាក់អំពីការទិញ-លក់ ដីដែលមានក្បាលដីលេខ ០៥៨១ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ របស់សង្កាត់កូនក្រៀល ។

៥-រូបភាពការរៀបចំដីឲ្យក្លាយជាដីចំការលើដីដែលមានក្បាលដីលេខ ០៥៣៧ ។

៦-វិក្កយបត្រចំណាយលើការសំអាតដី ជីកស្រះ និងធ្វើផ្លូវលើដីដែលមានក្បាលដីលេខ ០៥៣៧ ។

៧-ភស្តុតាងជាសាក្សីចំនួន បី រូបមាន:

-ឈ្មោះ [redacted] នួន ភេទស្រី អាយុ ៥៦ឆ្នាំ ជនជាតិខ្មែរ ។

-ឈ្មោះ [redacted] ធី ភេទស្រី អាយុ ៥៣ឆ្នាំ ជនជាតិខ្មែរ ។

-ឈ្មោះ [redacted] សុខផល្លា ភេទស្រី អាយុ ៥៣ឆ្នាំ ជនជាតិខ្មែរ ។

**<u>សំអាងហេតុ</u>**

១-ពាក្យបណ្ដឹងអង្គសេចក្ដីចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់ដើមចោទឈ្មោះ [redacted] វីតា តុលាការអាចលើកយកមកធ្វើការទាញហេតុផលដោយផ្ទាល់មាត់បានតាមបញ្ញត្តិមាត្រា ១០ និងមាត្រា ២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-តាមចម្លើយដើមចោទ សេចក្ដីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ ចម្លើយសាក្សី នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ រួមនឹងការពិនិត្យភស្តុតាងជាឯកសារដែលមាននៅក្នុងសំណុំរឿងឃើញថា៖

**ការទាមទារចំណុច ១**

ដើមចោទឈ្មោះ [redacted] វីតា បានដាក់ពាក្យបណ្ដឹងលែងលះពីចុងចម្លើយឈ្មោះ [redacted] សុវត្ថិ កាលពីអំឡុងខែធ្នូ ឆ្នាំ២០១៩ នៅសាលាដំបូងខេត្តសៀមរាប រហូតតុលាការសម្រេចចេញសាលក្រមលេខ ០៦ (គ) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ ដោយសម្រេចឲ្យភាគីដើមចោទឈ្មោះ [redacted] វីតា លែងលះពីចុងចម្លើយឈ្មោះ [redacted] សុវត្ថិ ។ កំណត់យកដើមចោទឈ្មោះ [redacted] វីតា ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] សុភារក្ស ,ឈ្មោះ [redacted] មេត្តា និងឈ្មោះ [redacted] សេរី ។ ឲ្យចុងចម្លើយឈ្មោះ [redacted] សុវត្ថិ ផ្ដល់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព និងប្រគល់ទ្រព្យសម្បត្តិរួមដែលមានដីមួយកន្លែងដែលមានក្បាលដីលេខ



Scanned with CamScanner

២២០៤០៣១៦-០៥៨១ ស្ថិតនៅភូមិដងទង់ សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ ឲ្យដើមចោទឈ្មោះ [redacted] វីតា ជាអ្នកមានសិទ្ធិគ្រប់គ្រង និងចាត់ចែងជាកម្មសិទ្ធិ តាមការព្រមព្រៀង ។

-ការអះអាងរបស់ដើមចោទ ពាក់ព័ន្ធលើការភ័ន្តច្រឡំលើក្បាលដីដែលត្រូវបែងចែកក្នុងសាលក្រមលេខ ០៦ (គ) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ ដើមចោទឈ្មោះ [redacted] វីតា គួរគប្បីស្នើសុំ មកតុលាការឲ្យធ្វើការកែតម្រូវលើសាលក្រម ប៉ុន្តែដើមចោទបែរជាទុកឲ្យសាលក្រមនោះ ចូលជាស្ថាពរទៅវិញ ។ នេះជាករណីដែលភាគីមិនអនុវត្តសិទ្ធិដោយខ្លួនឯង ហើយបណ្តាលឲ្យសាលក្រមចូលជាស្ថាពរដែលអាចបណ្តាលឲ្យខូចខាតផលប្រយោជន៍ស្របច្បាប់របស់ខ្លួនដោយខ្លួនឯង ។

-ការទាមទាររបស់ដើមចោទឈ្មោះ [redacted] វីតា ដើម្បីសុំសិទ្ធិគ្រប់គ្រងដីដែលមានក្បាលដីលេខ ២២០៤០៣១៦-០៥៣៧ តែម្នាក់ឯង តុលាការយល់ឃើញថា មិនមានមូលដ្ឋានច្បាប់សារជាតុណាមួយដែលអនុញ្ញាតឲ្យដើមចោទមានសិទ្ធិទាមទារសុំជាកម្មសិទ្ធិតែម្នាក់ឯង ចំពោះដីដែលមានក្បាលដីលេខ ២២០៤០៣១៦-០៥៣៧ បានឡើយ ។

-នៅក្នុងសាលក្រមលេខ ០៦ (គ) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ បានសម្រេចបែងចែកទ្រព្យរួមតែលើដីដែលមានក្បាលដីលេខ ២២០៤០៣១៦-០៥៨១ ដោយពុំបានបែងចែកលើទ្រព្យរួមដែលជាដីដែលមានក្បាលដីលេខ ២២០៤០៣១៦-០៥៣៧ នោះទេ ហើយក្រោយពេលសាលក្រមលេខ ០៦ (គ) ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ បានចូលជាស្ថាពរ ទ្រព្យរួមដែលជាដីដែលមានក្បាលដីលេខ ២២០៤០៣១៦-០៥៣៧ បង្កើតអានុភាពដោយប្រែក្លាយពីទ្រព្យរួមទៅជាទ្រព្យអវិភាគ ហេតុដូច្នេះការទាមទាររបស់ដើមចោទឈ្មោះ [redacted] វីតា សុំគ្រប់គ្រងដីដែលមានក្បាលដីលេខ ២២០៤០៣១៦-០៥៣៧ តែម្នាក់ឯង គប្បីតុលាការធ្វើការច្រានចោលការទាមទារ ស្របតាមបញ្ញត្តិមាត្រា ២០២ និងមាត្រា ២០៣ នៃក្រមរដ្ឋប្បវេណី ។

**ការទាមទារចំណុច ២**

ដើមចោទបានសុំជាអ្នកទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី និងប្រាក់ពន្ធតាមច្បាប់កំណត់ ត្រង់ចំណុចនេះចុងចម្លើយបានឯកភាព ហេតុដូច្នេះ តុលាការគប្បីសម្រេចឲ្យដើមចោទទទួលបន្ទុកលើប្រាក់ប្រដាប់ក្តីតាមការព្រមព្រៀង ។

**ការទាមទារចំណុច ៣**

ដើមចោទប្តឹងសុំឲ្យតុលាការចេញសាលក្រមអាចអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុចទី១ដោយហេតុថាដើម្បីជៀសវាងការអូសបន្លាយពេលវេលានិងភាពចាំបាច់តាមមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីតែចុងចម្លើយមិនឯកភាព ។ ត្រង់ចំណុចនេះតុលាការយល់ឃើញថា មិនទាន់មានភាពចាំបាច់តាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីទេ ដោយទុកសិទ្ធិឲ្យភាគីមានលទ្ធភាពអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន ហើយបើតុលាការសម្រេចច្រានចោលការទាមទារត្រង់ចំណុចទី១ នៃការទាមទាររបស់ភាគីដើមចោទ ការអនុវត្តជាបណ្តោះអាសន្នក៏មិនអាចកើតឡើងដែរ ហេតុដូច្នេះតុលាការគប្បីសម្រេចច្រានចោលការទាមទារត្រង់ចំណុចនេះនៅក្នុងសេចក្តីសម្រេចនៃសាលក្រម ។

៣-បណ្តឹងតបចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ របស់ម្ចាស់បណ្តឹងតបឈ្មោះ [redacted] សុវត្ថិ និងជាចុងចម្លើយគឺៈ



Scanned with CamScanner

ចំពោះការទាមទារក្នុងបណ្តឹងតបរបស់ចុងចម្លើយត្រង់ចំណុច ក ,ចំណុច ខ ,ចំណុច គ ,ចំណុច ឃ និងចំណុច ង គឺគ្រាន់តែជាមធ្យោបាយតទល់ដែលចុងចម្លើយ ត្រូវធ្វើការអះអាង និងស្នើសុំឲ្យតុលាការពិនិត្យភស្តុតាងនៅក្នុងនីតិវិធីបណ្តឹងតែប៉ុណ្ណោះ ហើយចុងចម្លើយក៏បានធ្វើរួចហើយដែរ ហេតុនេះគប្បីតុលាការសម្រេចច្រានចោលការទាមទារក្នុងបណ្តឹងតបរបស់ចុងចម្លើយត្រង់ចំណុច ក ,ចំណុច ខ ,ចំណុច គ ,ចំណុច ឃ និងចំណុច ង ក្នុងបណ្តឹងតបចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ របស់ចុងចម្លើយ ។

**<u>សេចក្តីសម្រេចបញ្ចប់</u>**

**១**-ច្រានចោលការទាមទារនៅក្នុងពាក្យបណ្តឹងចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២១ របស់ដើមចោទឈ្មោះ [redacted] **ថវតា** ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ៥១ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តសៀមរាប ។

**២**-ច្រានចោលការទាមទារនៅក្នុងពាក្យបណ្តឹងតបចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ របស់ដើមបណ្តឹងតបឈ្មោះ [redacted] **សុវត្ថា** ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ៥១ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តសៀមរាប ។

**៣**-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

-សាលក្រមនេះ បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១ ចំពោះមុខគូភាគី និងប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ ។

-បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រម |
|---|---|
| **ហត្ថលេខា និងត្រា** [redacted] | **ហត្ថលេខា និងត្រា** [redacted] |

---

បានឃើញ

**ចៅក្រម**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ០៣រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

សៀមរាប,ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

បានថតចម្លងត្រឹមត្រូវចេញពីច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី

សៀមរាប ថ្ងៃទី០៥ ខែ...ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner